# الدروس المهمة لعامة الأمة

# មេរៀនសំខាន់ៗសម្រាប់សាធារណជនទូទៅ

## មេរៀនសំខាន់ៗសម្រាប់សាធារណជនទូទៅ

អាប់ទុលអាហ្ស៊ីស ពិន អាប់ទុលឡោះ ពិន ហ្ពាហ្ស

## មេរៀនសំខាន់ៗសម្រាប់សាធារណជនទូទៅ

របស់សាសនវិទូឥស្លាម

អាប់ទុលអាហ្ស៊ីស ពិន អាប់ទុលឡោះ ពិន ហ្ពាហ្ស

សូមអល់ឡោះជាម្ចាស់មេត្តាប្រោសប្រទាននូវក្តីមេត្តាករុណាដល់គាត់

بسم الله الرحمن الرحيم

## អារម្ភកថាអ្នកនិពន្ធ

រាល់ការសរសើរទាំងឡាយ

គឺសម្រាប់អល់ឡោះជាព្រះជាម្ចាស់នៃពិភពទាំងអស់។ ហើយលទ្ធផលចុងក្រោយដ៏ល្អប្រសើរ

គឺសម្រាប់បណ្តាអ្នកដែលកោតខ្លាចអល់ឡោះ។ សូមសន្តិភាព និងពរជ័យកើតមានដល់ខ្ញុំបម្រើ

និងជាអ្នកនាំសាររបស់ទ្រង់ ណាពីយើង មូហាំម៉ាត់ ព្រមទាំងក្រុមគ្រួសារ និងសហាហ្ពាត់របស់លោកទាំងអស់។

ជាបន្តមកទៀតៈ

នេះគឺជាពាក្យពេចន៍សង្ខេបដែលបកស្រាយនូវប្រការមួយចំនួនដែលសាធារណជនទូទៅចាំបាច់ត្រូវដឹងទាក់ទងនឹងសាសនាអ៊ីស្លាម

ដែលខ្ញុំបានឲ្យឈ្មោះថា

មេរៀនសំខាន់ៗសម្រាប់សាធារណជនទូទៅ។

យើងខ្ញុំសូមបួងសួងពីអល់ឡោះជាម្ចាស់

សូមទ្រង់មេត្តាផ្តល់ជាប្រយោជន៍ដល់បណ្តាជនមូស្លីមតាមរយៈកិច្ចការនេះ

ហើយសូមទ្រង់មេត្តាទទួលយកនូវកិច្ចខិតខំប្រឹងប្រែងនេះពីយើងខ្ញុំផងចុះ។ ពិតប្រាកដណាស់

ទ្រង់មហាសប្បុរស មហាឧត្តុង្គឧត្តម។

អាប់ទុលអាហ្ស៊ីស ពិន

អាប់ទុលឡោះ ពិន ហ្ពាហ្ស

មេរៀនសំខាន់ៗសម្រាប់សាធារណជនទូទៅ[1]

## មេរៀនទី១៖ ស៊ូរ៉ោះ

## អាល់ហ្វាទីហះ រួមនឹងស៊ូរ៉ោះខ្លីៗមួយចំនួន

ស៊ូរ៉ោះ

អាល់ហ្វាទីហះ

រួមនឹងស៊ូរ៉ោះខ្លីៗមួយចំនួនទៀតតាមដែលអាចធ្វើបាន ចាប់ពីស៊ូរ៉ោះ អាហ្សហ្សាល់ហ្សាឡះ

រហូតដល់ស៊ូរ៉ោះ អាន់ណាស ដោយមានការបង្ហាត់បង្រៀនឱ្យសូត្រតាម

កែតម្រូវការសូត្រ ទន្ទេញចាំមាត់

ហើយនិងពន្យល់បកស្រាយនូវអ្វីដែលចាំបាច់ត្រូវយល់ដឹង។

---

[1] ម៉ាច្មូអហ្វាតាវ៉ា វ៉ាម៉ាក៏ឡាត ម៉ូតាណាវវីអះ (៣/២៨៨-២៩៨)។

## មេរៀនទី២៖

## គោលគ្រឹះនៃសាសនាអ៊ិស្លាម

បញ្ជាក់អំពីគោលគ្រឹះ(រូកុន)ទាំងប្រាំនៃសាសនាអ៊ិស្លាម។

គោលគ្រឹះទីមួយ

និងជាគោលគ្រឹះដែលធំធេងជាងគេបំផុតនោះគឺ៖ ពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទទួលស្គាល់ថា

គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ

ហើយមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ(لا إله إلا الله، محمد رسول الله) ជាមួយនឹងការពន្យល់ពីអត្ថន័យរបស់វា

ព្រមទាំងការបញ្ជាក់អំពីលក្ខខណ្ឌនៃពាក្យ "لا إله إلا الله"(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ

លើកលែងតែអល់ឡោះ)។

ចំពោះអត្ថន័យរបស់ពាក្យនេះ គឺ៖ "لا إله" (គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ) គឺជាការបដិសេធរាល់អ្វីទាំងឡាយដែលត្រូវបានគេគោរពសក្ការៈក្រៅពីអល់ឡោះ,

“إِلَّا الله” (លើកលែងតែអល់ឡោះ) ជាការទទួលស្គាល់នូវការគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់តែមួយអង្គគត់ដោយគ្មានដៃគូសម្រាប់ទ្រង់ឡើយ។ ចំណែកឯលក្ខខណ្ឌនៃពាក្យ

“لا إله إلا الله”

(គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ)

វិញគឺ៖ ត្រូវមានចំណេះដឹង ផ្ទុយពីការមិនដឹង, ត្រូវមានជឿជាក់យ៉ាងមុតមាំ

ផ្ទុយពីការសង្ស័យ, ត្រូវមានភាពជ្រះថ្លាបរិសុទ្ធ ផ្ទុយនឹងអំពើពហុទេវនិយម,

ត្រូវមានភាពទៀងត្រង់ ផ្ទុយនឹងការកុហក, ត្រូវមានក្ដីស្រឡាញ់ ផ្ទុយនឹងការមិនពេញចិត្ត

ឬស្អប់ខ្ពើម, ត្រូវតែអនុវត្តតាម ផ្ទុយនឹងការបោះបង់, ត្រូវតែទទួលយក ផ្ទុយនឹងការបដិសេធ

ហើយនិងប្រឆាំងចំពោះអ្វីដែលត្រូវបានគេគោរពសក្ការៈក្រៅពីអល់ឡោះជាម្ចាស់។ លក្ខខណ្ឌទាំងនេះត្រូវបានចងក្រងជាឃ្លាកំណាព្យភាសាអារ៉ាប់ចំនួនពីរឃ្លាដែលមានអត្ថន័យដូចខាងក្រោម៖

علمٌ يقينٌ وإخلاصٌ وصدقُك مَعْ ...محبةٍ وانقيادٍ والقَبولِ لها

“ចំណេះដឹង

ការជឿជាក់យ៉ាងមុតមាំ ភាពជ្រះថ្លា និងភាពទៀងត្រង់របស់អ្នក ព្រមជាមួយនឹងក្តីស្រឡាញ់ ការអនុវត្តតាម និងការទទួលយកចំពោះលក្ខខណ្ឌទាំងនេះ។ وَزِيدَ ثامنُها الكُفرانُ منك بِمَا ...سِوَى الإِلهِ مِنَ الأشياءِ قَد أُلِهَا

ហើយលក្ខខណ្ឌទីប្រាំបីដែលត្រូវបានបន្ថែម គឺការប្រឆាំងរបស់អ្នកចំពោះអ្វីទាំងឡាយដែលត្រូវបានគេគោរពសក្ការៈក្រៅពីអល់ឡោះជាម្ចាស់”។ ព្រមទាំងការបញ្ជាក់អំពីពាក្យសក្ខីកម្មទទួលស្គាល់ថា

“មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ” (محمد رسول الله) និងលក្ខខណ្ឌតម្រូវរបស់វា នោះគឺ៖ ត្រូវជឿជាក់លើលោកចំពោះអ្វីដែលលោកបានប្រាប់ ប្រតិបត្តិតាមលោកនូវអ្វីដែលលោកបានបង្គាប់ប្រើ

ជៀសវាងនូវអ្វីដែលលោកបានហាមឃាត់និងព្រមាន

ហើយត្រូវគោរពសក្ការៈចំពោះអល់ឡោះស្របទៅតាមអ្វីដែលអល់ឡោះជាម្ចាស់

និងអ្នកនាំសាររបស់ទ្រង់ ﷺ បានបញ្ញត្តិ។ បន្ទាប់មក

ត្រូវបញ្ជាក់ប្រាប់ដល់អ្នកសិក្សានូវគោលគ្រឹះផ្សេងទៀតដែលនៅសល់ក្នុងចំណោមគោលគ្រឹះទាំងប្រាំនៃសាសនាអ៊ិស្លាម

ដែលរួមមាន៖ ការប្រតិបត្តិសឡាត ការបរិច្ចាគហ្សាកាត់ ការបួសខែរ៉ម៉ាហ្ទន

និងការធ្វើធម្មយាត្រាហាជ្ជីនៅពៃតុលហារ៉ម(ក្រុងម៉ាក្កះ)សម្រាប់អ្នកដែលមានលទ្ធភាព។

## មេរៀនទី៣៖ គោលគ្រឹះនៃជំនឿ

គោលគ្រឹះនៃជំនឿ(រូកុនអ៊ីម៉ាន)មានប្រាំមួយប្រការគឺ៖

ត្រូវមានជំនឿចំពោះអល់ឡោះ

បណ្ដាម៉ាឡាអ៊ីកាត់(ទេវតា)របស់ទ្រង់

បណ្ដាគម្ពីររបស់ទ្រង់

បណ្ដាអ្នកនាំសាររបស់ទ្រង់

មានជំនឿចំពោះថ្ងៃបរលោក

និងមានជំនឿចំពោះវាសនាល្អអាក្រក់ថាមកពីអល់ឡោះជាម្ចាស់។

## មេរៀនទី៤៖ ប្រភេទនៃតាវហេទ និងប្រភេទនៃអំពើស្ហ៊ីរិក

បញ្ជាក់អំពីប្រភេទនៃតាវហេទ(ឯកទេវនិយម) ដែលមានបីប្រភេទ គឺតាវហេទរូពូពីយ៉ះ តាវហេទអ៊ូលូហ៊ីយ៉ះ និងតាវហេទអាល់អាស្មាក វ៉ាសស៊ីហ្វាត។

១. តាវហេទរូពូពីយ៉ះ (ឯកទេវនិយមចំពោះការបង្កើត)៖

គឺត្រូវមានជំនឿថា អល់ឡោះជាម្ចាស់ គឺជាអ្នកបង្កើតនូវរាល់អ្វីៗទាំងអស់ និងជាអ្នកចាត់ចែងរាល់អ្វីៗទាំងអស់ដោយពុំមានដៃគូណាមួយរួមជាមួយនឹងទ្រង់ក្នុងកិច្ចការនេះឡើយ។

២. តាវហេទ អ៊ូលូហ៊ីយ៉ះ(ឯកទេវនិយមចំពោះការគោរពសក្ការ:)៖

គឺត្រូវមានជំនឿថា អល់ឡោះជាម្ចាស់ទ្រង់គឺជាអ្នកដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ ដោយគ្មានដៃគូរួមជាមួយទ្រង់នៅក្នុងប្រការនេះឡើយ។ នេះហើយជាអត្ថន័យពិតប្រាកដនៃពាក្យ “لا إله إلا الله” ដែលមានអត្ថន័យថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះ។

ដូចនេះ រាល់ការគោរពសក្ការៈទាំងអស់ ដូចជាការសឡាត(ថ្វាយបង្គំ) ការបួសតមអាហារ ក៏ដូចជាប្រការផ្សេងៗទៀត

គឺចាំបាច់ត្រូវធ្វើឡើងដោយចិត្តស្មោះសចំពោះអល់ឡោះជាម្ចាស់តែមួយគត់

ហើយមិនអនុញ្ញាតឱ្យបង្វែរអ្វីមួយអំពីការគោរពសក្ការៈនេះទៅចំពោះអ្វីផ្សេងក្រៅពីទ្រង់ឡើយ។

៣. តាវហេទ អាល់អាស្មាក

វ៉ាសស៊ីហ្វាត (ឯកទេវនិយមចំពោះព្រះនាម និងលក្ខណៈរបស់ទ្រង់)៖

គឺត្រូវមានជំនឿចំពោះរាល់ព្រះនាម និងលក្ខណៈសម្បត្តិ(ស៊ីហ្វាត)ទាំងឡាយរបស់អល់ឡោះ

ដែលមានភស្តុតាងបញ្ជាក់នៅក្នុងគម្ពីរគួរអានដ៏ឧត្តុង្គឧត្តម ឬក្នុងហាទីស្ហដែលត្រឹមត្រូវពិតប្រាកដ(សហេស)

ហើយត្រូវទទួលស្គាល់នាម និងលក្ខណៈទាំងអស់នោះសម្រាប់តែអល់ឡោះជាម្ចាស់មួយគត់ស្របតាមលក្ខណៈដែលសក្តិសមទៅនឹងភាពបរិសុទ្ធរបស់ទ្រង់

ដោយគ្មានការកែប្រែ បដិសេធ ចង់ដឹងពីរបៀប ឬក៏ប្រៀបប្រដូចឡើយ

អនុវត្តតាមបន្ទូលរបស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា៖

﴿قُلۡ هُوَ ٱللَّهُ أَحَدٌ 1 ٱللَّهُ ٱلصَّمَدُ 2 لَمۡ يَلِدۡ وَلَمۡ يُولَدۡ 3 وَلَمۡ يَكُن لَّهُۥ كُفُوًا أَحَدُۢ 4﴾

“ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថា៖

អល់ឡោះគឺជាព្រះជាម្ចាស់(ដែលគេត្រូវគោរពសក្ការៈ)តែមួយគត់។

អល់ឡោះទ្រង់ជាទីពឹងពាក់។

ទ្រង់មិនប្រសូតបុត្រ ហើយទ្រង់ក៏មិនត្រូវបានគេប្រសូតមកនោះដែរ។

ហើយគ្មាននរណាម្នាក់អាចប្រៀបប្រដូចនឹងទ្រង់បានឡើយ”។ [គម្ពីរគួរអាន ១១២:១-៤] ទ្រង់បានមានបន្ទូលទៀតថាៈ

﴿...لَيۡسَ كَمِثۡلِهِۦ شَيۡءٞۖ وَهُوَ ٱلسَّمِيعُ ٱلۡبَصِيرُ﴾

“គ្មានអ្វីមួយអាចប្រដូចនឹងទ្រង់បានឡើយ។ ហើយទ្រង់មហាឮ មហាឃើញបំផុត”។ [គម្ពីរគួរអាន ៤២:១១]

មានសាសនវិទូឥស្លាមមួយចំនួនបានធ្វើការបែងចែកតាវហេទទៅជាពីរប្រភេទប៉ុណ្ណោះ ដោយបានបញ្ចូលតាវហេទអាល់អាស្មាក វ៉ាសស៊ីហ្វាត ទៅក្នុងតាវហេទរូពូពីយ៉ះ។ ការបែងចែកបែបនេះ ក៏គ្មានការប្រកែក ឬទាស់ខុសអ្វីនោះឡើយ ព្រោះគោលបំណង គឺច្បាស់លាស់ដូចគ្នានៅក្នុងវិធីសាស្រ្តបែងចែកទាំងពីរប្រភេទនេះ។

ចំណែកឯអំពើស្ហ៊ីរិក(ពហុទេវនិយម)វិញ មានបីប្រភេទគឺ ស្ហ៊ីរិកធំ(ពហុទេវនិយមកម្រិតធ្ងន់) ស្ហ៊ីរិកតូច(ពហុទេវនិយមកម្រិតស្រាល) និងស្ហ៊ីរិកលាក់កំបាំង(ពហុទេវនិយមដោយលាក់បាំង)។

ស្ហ៊ីរិកធំ ឬពហុទេវនិយមកម្រិតធ្ងន់ គឺធ្វើឲ្យទង្វើកុសលទាំងឡាយក្លាយជាអសារបង់ ហើយនិងត្រូវទទួលនូវអមតភាពនៅក្នុងឋាននរក សម្រាប់ជនណាដែលបានស្លាប់ក្នុងស្ថានភាពបែបនេះ

ដូចដែលអល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖

﴿...وَلَوۡ أَشۡرَكُواْ لَحَبِطَ عَنۡهُم مَّا كَانُواْ يَعۡمَلُونَ﴾

“តែប្រសិនបើពួកគេបានធ្វើស្ហ៊ីរិកវិញនោះ ទង្វើ(កុសល)ទាំងឡាយដែលពួកគេធ្លាប់បានសាងនឹងត្រូវចាត់ទុកជាអសារបង់ជាមិនខាន”។ [គម្ពីរគួរអាន ៦:៨៨] ទ្រង់បានមានបន្ទូលទៀតថា៖

﴿مَا كَانَ لِلۡمُشۡرِكِينَ أَن يَعۡمُرُواْ مَسَٰجِدَ ٱللَّهِ شَٰهِدِينَ عَلَىٰٓ أَنفُسِهِم بِٱلۡكُفۡرِۚ أُوْلَٰٓئِكَ حَبِطَتۡ أَعۡمَٰلُهُمۡ وَفِي ٱلنَّارِ هُمۡ خَٰلِدُونَ17﴾

“មិនសក្តិសមឡើយសម្រាប់ពួកពហុទេវនិយមក្នុងការកសាង និងថែទាំបណ្តាម៉ាស្ជិតរបស់អល់ឡោះ ទាំងដែលពួកគេជាអ្នកដែលទទួលស្គាល់លើខ្លួនឯងនូវភាពគ្មានជំនឿនោះ។ ពួកទាំងនោះ ទង្វើរបស់ពួកគេនឹងក្លាយជាអសារបង់ ហើយពួកគេនឹងត្រូវស្ថិតក្នុងឋាននរកជាអមតៈ”។ [គម្ពីរគួរអាន ៩:១៧] ជាការពិតណាស់ ជនណាដែលបានស្លាប់ដោយនាំទៅជាមួយនូវអំពើអំពើស្ហ៊ីរិកនេះ

គេនឹងមិនអភ័យទោសឱ្យជននោះដាច់ខាត ហើយឋានសួគ៌ គឺត្រូវបានហាមឃាត់សម្រាប់រូបគេ ដូចដែលអល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖

﴿إِنَّ ٱللَّهَ لَا يَغۡفِرُ أَن يُشۡرَكَ بِهِۦ وَيَغۡفِرُ مَا دُونَ ذَٰلِكَ لِمَن يَشَآءُ...﴾

“ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មិនអភ័យទោសឱ្យអ្នកដែលធ្វើស្ហ៊ីរិកចំពោះទ្រង់ឡើយ តែទ្រង់នឹងអភ័យទោសឱ្យចំពោះបាបកម្មផ្សេងពីនេះ ចំពោះជនណាដែលទ្រង់មានចេតនា”។ [គម្ពីរគួរអាន ៤:៤៨] ទ្រង់បានមានបន្ទូលទៀតថា៖

﴿...إِنَّهُۥ مَن يُشۡرِكۡ بِٱللَّهِ فَقَدۡ حَرَّمَ ٱللَّهُ عَلَيۡهِ ٱلۡجَنَّةَ وَمَأۡوَىٰهُ ٱلنَّارُۖ وَمَا لِلظَّٰلِمِينَ مِنۡ أَنصَارٖ﴾

“ពិតប្រាកដណាស់ ជនណាហើយដែលបានធ្វើស្ហ៊ីរិក(ពហុទេវនិយម)នឹងអល់ឡោះនោះ អល់ឡោះជាម្ចាស់ពិតជាបានដាក់បម្រាមលើរូបគេមិនឱ្យចូលឋានសួគ៌ឡើយ ហើយកន្លែងស្នាក់អាស្រ័យរបស់គេ គឺឋាននរក។ ហើយសម្រាប់ពួកដែលបំពាន គឺគ្មានអ្នកជួយឡើយ”។ [គម្ពីរគួរអាន ៥:៧២]

ស្ថិតក្នុងចំណោមប្រភេទរបស់វានោះមានដូចជា ការបួងសួងសុំពីអ្នកស្លាប់ និងរូបសំណាក ការសុំជំនួយពីពួកគេ សច្ចាបន់ចំពោះពួកគេ សំឡេះសត្វថ្វាយចំពោះពួកគេ ក៏ដូចជាប្រការផ្សេងទៀតដែលស្រដៀងគ្នានេះ។

ស្ហ៊ីរិកតូច ពហុទេវនិយមកម្រិតស្រាល

គឺជាប្រការទាំងឡាយណាដែលមានភស្តុតាងពីគម្ពីរគួរអាន ឬស៊ុណ្ណះពីការឲ្យឈ្មោះវាថាជាអំពើអំពើស្ហ៊ីរិក(ពហុទេវនិយម)

ប៉ុន្តែវាមិនស្ថិតក្នុងចំណោមប្រភេទនៃស្ហ៊ីរិកធំឡើយ ដូចជារីយ៉ាក(ធ្វើអំពើល្អណាមួយដើម្បីគ្រាន់តែចង់ឲ្យគេមើលឃើញ)

ការស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ និងការនិយាយថា៖ “អ្វីដែលអល់ឡោះប្រាថ្នា និងបុគ្គលនោះប្រាថ្នា (វានឹងកើតឡើង)” ជាដើម ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«أَخْوَفُ مَا أَخَافُ عَلَيْكُمْ الشِّرْكُ الْأَصْغَرُ» فَسُئِلَ عَنْهُ، فَقَالَ: «الرِّيَاءُ»[2]

«អ្វីដែលខ្ញុំខ្លាចបំផុតចំពោះពួកអ្នកគឺស្ហ៊ីរិកតូច»។ នៅពេលដែលគេសួរលោកអំពីវា លោកបានឆ្លើយថា៖ «គឺរីយ៉ាក»។[1] រាយការណ៍ដោយ អ៊ីម៉ាំអះម៉ាត់

[1] រាយការណ៍ដោយ អ៊ីម៉ាំអះម៉ាត់ (៥/៤២៨), អាត់តប់រ៉នី ក្នុងសៀវភៅ អាល់កាពៀរ (៤/៣៣៨) និង អាល់បៃហាគី ក្នុងសៀវភៅ អាសស៊្ហូអាប់ (១៤/៣៥៥)។ មានលើកឡើងក្នុងសៀវភៅ ម៉ាចូម៉ាក់ អាសហ្សាវ៉ាអ៊ិទ(១/១២១)

អាត់តប់រ៉នី និងអាល់ពៃហាគី ពីលោក ម៉ះមូទ ពិន ឡាពីត អាល់អាន់សរី رضي الله عنه ដោយបណ្ដាញអ្នករាយការណ៍ល្អ(អ៊ិសណាទជៃយិទ) និងរាយការណ៍ដោយ អាត់តប់រ៉នី ដោយបណ្ដាញអ្នករាយការណ៍ជាច្រើនដែលល្អ ពីលោក ម៉ះមូទ ពិន ឡាពីត
អំពី រ៉ហ្វៀក ពិន ខទីចូ អំពីណាពី ﷺ។
  លោកបានមានប្រសាសន៍ទៀតថា៖
«مَنْ حَلَفَ بِشَيْءٍ دُونَ اللَّهِ فَقَدْ أَشْرَكَ»[3]
“ជនណាដែលបានស្បថនឹងអ្វីមួយក្រៅពីអល់ឡោះ ជននោះពិតជាបានធ្វើស្ហ៊ីរិកហើយ”។[1]
រាយការណ៍ដោយ អ៊ីម៉ាំអះម៉ាត់ ដោយបណ្ដាញអ្នករាយការណ៍ត្រឹមត្រូវ(អ៊ិសណាទសហេស) អំពី អ៊ូមើរ ពិន អាល់ខត្តប h ហើយរាយការណ៍ដោយ អាពូហ្ទាវូទ និងអាត់តៀរមីហ្ស៊ី ដោយបណ្ដាញអ្នករាយការណ៍ត្រឹមត្រូវ(អ៊ិសណាទសហេស) ពីហាទីស អ៊ិពនូអ៊ូមើរ رضي الله عنهما អំពីណាពី ﷺ ពិតណាស់ លោកបានមានប្រសាសន៍ថា៖
«مَنْ حَلَفَ بِغَيْرِ اللَّهِ فَقَدْ كَفَرَ أَوْ أَشْرَكَ»[4]

---

ថា៖ រាយការណ៍ដោយអះម៉ាត់ ហើយខ្សែបណ្ដាញអ្នករាយការណ៍ហាទីស្ហនេះ គឺជាអ្នករាយការណ៍ដែលមានភាពស្មោះត្រង់និងគួរឲ្យទុកចិត្តបានកម្រិតខ្ពស់(សហេស)។

1 រាយការណ៍ដោយ អ៊ីម៉ាំអះម៉ាត់ (១/៤៧)។

“ជនណាដែលបានស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ ជននោះពិតជាបានបោះបង់ជំនឿ(កាហ្វៀរ) ឬបានធ្វើស្ហ៊ីរិកហើយ”។[1]
លោកបានមានប្រសាសន៍ផងដែរថា៖
[5]«لا تَقُولُوا: مَا شَاءَ اللَّهُ وَشَاءَ فُلاَنٌ، وَلَكِنْ قُولُوا: مَا شَاءَ اللَّهُ ثُمَّ شَاءَ فُلاَنٌ»
“ចូរពួកអ្នកកុំនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា និងបុគ្គលនោះមានចេតនា(វានឹងកើតឡើង)។ ក៏ប៉ុន្តែពួកអ្នកត្រូវនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា(វានឹងកើតឡើង)។ បន្ទាប់មក ទើបបុគ្គលនោះមានចេតនា”។[2] រាយការណ៍ដោយ អាពូហ្ទាវូទ ដោយបណ្តាញអ្នករាយការណ៍ដែលត្រឹមត្រូវ(អ៊ិសណាទសហេស) អំពី ហ៊ូហៃហ្វះ ពិន អាល់យ៉ាម៉ាន رضي الله عنه ។
ស្ហ៊ីរិកប្រភេទនេះមិនធ្វើឲ្យចេញពីសាសនា(មួរតាត់)ឡើយ ហើយក៏មិនធ្វើឲ្យបុគ្គលនោះស្ថិតនៅជាអមតៈក្នុងឋាននរកនោះដែរ។ ប៉ុន្តែវាធ្វើឱ្យប៉ះពាល់ដល់ភាពពេញលេញនៃតាវហេទដែលជាកាតព្វកិច្ច។

[1] រាយការណ៍ដោយ អាពូហ្ទាវូទ:៣២៥១ និងអាត់តៀរមីហ្ស៊ី:១៥៣៥។
[2] រាយការណ៍ដោយ អាពូហ្ទាវូទ:៤៩៨០ និងអះម៉ាត់ (៥/៣៨៤)

ប្រភេទទីបី៖

ស្ហ៊ីរិកលាក់កំបាំង(ពហុទេវនិយមដោយលាក់បាំង)។

ភស្តុតាងរបស់វា គឺប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«أَلَا أُخْبِرُكُمْ بِمَا هُوَ أَخْوَفُ عَلَيْكُمْ عِنْدِي مِنَ المَسِيحِ الدَّجَّالِ؟» قَالُوا: بَلَى يَا رَسُولَ اللَّهِ، قَالَ: «الشِّرْكُ الخَفِيُّ، يَقُومُ الرَّجُلُ فَيُصَلِّي فَيُزَيِّنُ صَلاتَهُ لِمَا يَرَى مِنْ نَظَرِ الرَّجُلِ إِلَيْهِ»[6]

“តើពួកអ្នកចង់ឲ្យខ្ញុំប្រាប់អំពីអ្វីដែលខ្ញុំខ្លាចបំផុតចំពោះពួកអ្នកជាងម៉ាសៀហអាត់ហ្ជាច់ហ្ជាលដែរឬទេ”? ពួកគេបានឆ្លើយថា៖ ពិតមែនហើយ ឱរ៉សូលុលឡោះ។ លោកបានមានប្រសាសន៍ថា៖

“នោះគឺស្ហ៊ីរិកលាក់កំបាំង ដោយបុរសម្នាក់ក្រោកឈរសឡាត ហើយក៏សឡាតបានយ៉ាងល្អត្រឹមត្រូវ ដោយសារតែគេឃើញមានបុរសម្នាក់ទៀតកំពុងសម្លឹងមើលមកកាន់ខ្លួន”។

1

រាយការណ៍ដោយអ៊ីម៉ាំអះម៉ាត់ក្នុងសៀវភៅមុសណាត់របស់គាត់ ពីអាពូសាអ៊ីត អាល់ឃុទរី رضي الله عنه។

ហើយគេក៏អនុញ្ញាតឲ្យបែងចែកអំពើស្ហ៊ីរិកទៅជាពីរប្រភេទផងដែរ

គឺ៖

---

1 រាយការណ៍ដោយ អ៊ិពនូម៉ាហ្ជះ:៤២០៤ និងអ៊ីម៉ាំអះម៉ាត់ (៣/៣០)។

ស្ទីរិកធំ និងស្ទីរិកតូច។

ចំណែកឯស្ទីរិកលាក់កំបាំងវិញ គឺគ្របដណ្ដប់លើប្រភេទទាំងពីរនេះ។ វាអាចធ្លាក់ចូលទៅក្នុងស្ទីរិកធំ

ដូចជាស្ទីរិករបស់ពួកពុតត្បុត(មូណាហ្វិក) ពីព្រោះពួកគេលាក់បាំងនូវជំនឿខុសឆ្គងរបស់ខ្លួន

ហើយស្ដែងចេញឲ្យគេឃើញនូវភាពជាឥស្លាមដើម្បី គ្រាន់តែចង់ឲ្យអ្នកដទៃបានឃើញ(រិយ៉ាក)

និងដោយសារតែការភ័យខ្លាចចំពោះខ្លួនឯង។

ហើយវាក៏អាចស្ថិតក្នុងស្ទីរិកតូច

ដូចជារិយ៉ាក(ធ្វើល្អចង់ឲ្យគេឃើញ) ដូចមានក្នុងហាទីស្ហ ម៉ះមូទ ពិន ឡាពីត អាល់អាន់សរិ

ដែលបានលើកឡើងពីមុន និងហាទីស្ហ អាពូសាអ៊ីត ដែលបានលើកឡើងខាងលើ។ អល់ឡោះតែមួយគត់ដែលជាអ្នកចង្អុលបង្ហាញ។

## មេរៀនទី៥៖ អៀហសាន(អំពើល្អ)

គោលគ្រឹះ(រូកុន)នៃអៀហសាននោះគឺ

អ្នកត្រូវគោរពសក្ការៈចំពោះអល់ឡោះហាក់បីដូច ជាអ្នកមើលឃើញទ្រង់។

តែទោះបីអ្នកមិនឃើញទ្រង់ក៏ដោយ ក៏ជាក់ស្ដែង ទ្រង់កំពុងតែទតឃើញអ្នក។

## មេរៀនទី៦៖ លក្ខខណ្ឌនៃសឡាត

មានប្រាំបួនប្រការ៖

ឥស្លាម

មានសតិបញ្ញា ចេះដឹងខុសត្រូវ បំបាត់នូវហាហ្ទាស(ភាពកខ្វក់អរូបី) ជ្រះស្អាតពីភាពកខ្វក់(ណាជិស)

បិទបាំងរាងកាយ(អាវរ៉ាត់) ចូលដល់ពេលវេលា តម្រង់ទៅរកគិបឡាត់ និងការតាំងចិត្ត(នៀត)។

## មេរៀនទី៧៖ គោលគ្រឹះ(រូកុន)នៃសឡាត

មានដប់បួនប្រការ៖

ឈរសម្រាប់អ្នកដែលមានសមត្ថភាព

តឹកពៀរ៉ាតុលអៀហរ៉ម សូត្រស៊ូរ៉ោះអាល់ហ្វាទីហះ ឱនរូកុ ឈរត្រង់ខ្លួនបន្ទាប់ពីងើបពីរូកុ

ក្រាបស៊ូជោតលើអវយវៈទាំងប្រាំពីរ ងើបពីស៊ូជោតវិញ អង្គុយចន្លោះស៊ូជោតទាំងពីរ មានភាពនឹងនរនៅក្នុងគ្រប់កាយវិការទាំងអស់

អនុវត្តតាមលំដាប់លំដោយរវាងគោលគ្រឹះទាំងឡាយ សូត្រតះយិតចុងក្រោយ អង្គុយដើម្បីសូត្រតះយិតចុងក្រោយ

សឡាវ៉ាតលើណាពី ﷺ និងឲ្យសាឡាមចំនួនពីរដង។

## មេរៀនទី៨៖

## ប្រការចាំបាច់(វ៉ាជិប)នៃសឡាត

មានប្រាំបីប្រការ៖

គ្រប់តឹកពៀរទាំងអស់

ក្រៅពីតឹកពៀរ៉ាតុលអៀហរ៉ម, សូត្រថា៖ “سَمِعَ اللَّهُ لِمَنْ حَمِدَهُ” សម្រាប់អ៊ីម៉ាំ និងអ្នកសឡាតម្នាក់ឯង, សូត្រថា៖ “رَبَّنَا وَلَكَ الحَمْدُ” ទាំងសម្រាប់អ៊ីម៉ាំ ម៉ាក់មុម

និងអ្នកសទ្បាតម្នាក់ឯង, សូត្រថា៖ “سُبْحَانَ رَبِّيَ العَظِيْمِ”
ក្នុងពេលឱនរូកុ, សូត្រថា៖ “سُبْحَانَ رَبِّيَ الأَعْلَى”
ក្នុងពេលក្រាបស៊ូជោត, សូត្រថា៖ “رَبِّ اغْفِرْ لِي”
ក្នុងពេលអង្គុយចន្លោះស៊ូជោតទាំងពីរ,
សូត្រតះយិតទីមួយ
និងអង្គុយដើម្បីសូត្រតះយិតទីមួយ។

## មេរៀនទី៩៖ ពន្យល់អំពីការសូត្រតះយិត

គឺការសូត្រថា៖

“التَّحِيَّاتُ

لِلَّهِ، وَالصَّلَوَاتُ وَالطَّيِّبَاتُ، السَّلاَمُ عَلَيْكَ أَيُّهَا النَّبِيُّ وَرَحْمَةُ اللَّهِ وَبَرَكَاتُهُ، السَّلاَمُ عَلَيْنَا وَعَلَى عِبَادِ اللَّهِ الصَّالِحِينَ، أَشْهَدُ أَلَّا إِلَهَ إِلَّا اللَّهُ، وَأَشْهَدُ أَنَّ مُحَمَّدًا عَبْدُهُ وَرَسُولُهُ”

(ការគោរពតម្កើង

គឺសម្រាប់អល់ឡោះ ហើយការប្រតិបត្តិសទ្បាត និងសេចក្តីល្អទាំងឡាយ(ក៏សម្រាប់ទ្រង់ដែរ)។

សូមសន្តិភាព ក្តីមេត្តាករុណារបស់អល់ឡោះ និងពរជ័យរបស់ទ្រង់កើតមានដល់លោកឱណាពី(មូហាំម៉ាត់)។

សូមសន្តិភាពកើតមានដល់ពួកយើង និងបណ្តាខ្ញុំបម្រើរបស់អល់ឡោះដែលជាអ្នកសាងទង្វើកុសលទាំងឡាយ។

ខ្ញុំសូមធ្វើសាក្សីថា គ្មានព្រះជាម្ចាស់ឯណាដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ

ហើយខ្ញុំសូមធ្វើសាក្សីទៀតថា ពិតណាស់ មូហាំម៉ាត់ គឺជាខ្ញុំបម្រើ

និងជាអ្នកនាំសាររបស់ទ្រង់)។

បន្ទាប់មក ត្រូវសឡាវ៉ាតលើណាពី ﷺ និងសុំពរជ័យដល់លោក ដោយសូត្រថា៖ “اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ، وَعَلَى آلِ مُحَمَّدٍ، كَمَا صَلَّيْتَ عَلَى إِبْرَاهِيمَ وَعَلَى آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ، وَبَارِكْ عَلَى مُحَمَّدٍ، وَعَلَى آلِ مُحَمَّدٍ، كَمَا بَارَكْتَ عَلَى إِبْرَاهِيمَ، وَعَلَى آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ”

(ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាសឡាវ៉ាត(លើកសរសើរ)ទៅចំពោះមូហាំម៉ាត់

និងក្រុមគ្រួសាររបស់មូហាំម៉ាត់ ដូចដែលទ្រង់បានសឡាវ៉ាតទៅចំពោះអ៊ីព្រហ៊ីម

និងក្រុមគ្រួសាររបស់អ៊ីព្រហ៊ីមផង។ ពិតណាស់ ទ្រង់គឺជាអ្នកដែលត្រូវគេកោតសរសើរ

និងលើកតម្កើង។ ហើយសូមទ្រង់ប្រទានពរជ័យដល់មូហាំម៉ាត់ និងក្រុមគ្រួសាររបស់មូហាំម៉ាត់

ដូចដែលទ្រង់បានប្រទានពរជ័យដល់អ៊ីព្រាហ៊ីម និងក្រុមគ្រួសាររបស់អ៊ីព្រាហ៊ីមផង។ ពិតណាស់ ទ្រង់គឺជាអ្នកដែលត្រូវគេកោតសរសើរ និងលើកតម្កើង។)

នៅក្នុងតះយិតចុងក្រោយ បន្ទាប់ពីសូត្រដូចនេះរួច

គេត្រូវសុំការបញ្ចៀសអំពីអល់ឡោះពីទណ្ឌកម្មនៃនរកជើហាន់ណាំ ទណ្ឌកម្មនៅក្នុងផ្នូរ

ភាពវឹកវរនៅក្នុងជីវិតរស់នៅនិងពេលស្លាប់

និងពីភាពវឹកវរដែលបណ្តាលមកពីម៉ាសៀហអាត់ហ្ទាច់ហ្ជាល។ បន្ទាប់មក គេអាចជ្រើសរើសពាក្យបួងសួង(ទូអា)ណាមួយក៏បានតាមក្តីប្រាថ្នា

ជាពិសេស ពាក្យបួងសួង(ទូអា)ដែលមានភស្តុតាងបញ្ជាក់ពីណាពី ﷺ ដែលក្នុងនោះមានដូចជា៖

"اللَّهُمَّ أَعِنِّي عَلَى ذِكْرِكَ وَشُكْرِكَ وَحُسْنِ عِبَادَتِكَ، اللَّهُمَّ إِنِّي ظَلَمْتُ نَفْسِي ظُلْمًا كَثِيرًا، وَلَا يَغْفِرُ الذُّنُوبَ إِلَّا أَنْتَ، فَاغْفِرْ لِي مَغْفِرَةً مِنْ عِنْدِكَ، وَارْحَمْنِي إِنَّكَ أَنْتَ الْغَفُورُ الرَّحِيمُ"

(ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាជួយខ្ញុំឲ្យរលឹកដល់ទ្រង់ ដឹងគុណទ្រង់ និងគោរពសក្ការៈចំពោះទ្រង់ឲ្យបានល្អផង។ ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំបានបំពានចំពោះខ្លួនឯងយ៉ាងច្រើនលើសលប់។ ហើយគ្មាននរណាអាចអភ័យទោសចំពោះបាបកម្មទាំងឡាយក្រៅពីទ្រង់ឡើយ។ ហេតុនេះ សូមទ្រង់មេត្តាអភ័យទោសដល់ខ្ញុំជាការអភ័យទោសពីទ្រង់ និងសូមប្រោសប្រទាននូវក្តីមេត្តាករុណាចំពោះខ្ញុំផង។ ពិតប្រាកដណាស់ ទ្រង់គឺជាអ្នកអភ័យទោស មហាមេត្តាករុណាបំផុត)។

ចំណែកឯនៅក្នុងតះយិតទីមួយវិញ គេត្រូវក្រោកឈរឡើងទៅកាន់រ៉ក្អាត់ទីបី បន្ទាប់ពីពោលពាក្យសក្ខីកម្ម(ស្ហាហាហ្ទះ)ទាំងពីររួចចំពោះសឡាតហ្ញូហ្ញរ សឡាតអាសើរ សឡាតម៉ាហ្គ្រិប និងសឡាតអ៊ីស្ហា។ ប្រសិនបើគេសឡាវ៉ាតលើណាពី ﷺ ផងដែរនោះ វាគឺជាការប្រសើរ ដោយយោងលើភាពទូទៅនៃហាទីស្ហដែលទាក់ទងនឹងបញ្ហានេះ។ បន្ទាប់មក ទើបក្រោកឈរឡើងទៅកាន់រ៉ក្អាត់ទីបី។

## មេរៀនទី១០៖ ប្រការគប្បីធ្វើ(ស៊ូណ៊ិត)នៃសឡាត

ក្នុងចំណោមនោះមានដូចជា៖

១. ទូអាអ៊ិសទិហ្វតះ

២. ដាក់បាតដៃស្តាំលើដៃឆ្វេងនៅលើទ្រូងក្នុងពេលឈរ ទាំងមុនពេលរូកុ និងក្រោយពេលងើបពីរូកុ។

៣. លើកដៃទាំងពីរដោយដាក់ម្រាមដៃលាតត្រង់ និងផ្តុំចូលគ្នាឲ្យស្មើនឹងស្មា ឬស្មើនឹងត្រចៀកទាំងពីរនៅពេលតឹកពៀរលើកទីមួយ នៅពេលរូកុ ពេលងើបពីរូកុ និងនៅពេលក្រោកឈរពីតះយិតទីមួយបន្តទៅកាន់រ៉ក្អាត់ទីបី។

៤. សូត្របន្ថែមលើសពីមួយដងទៅលើការសូត្រក្នុងពេលរូកុ និងពេលស៊ូជោត។

៥. សូត្របន្ថែមទៅលើការសូត្រថា៖ "رَبَنَا وَلَكَ الحَمْدُ" បន្ទាប់ពីងើបឈរពីរូកុ និងសូត្របន្ថែមលើសពីមួយដងទៅលើពាក្យ “رَبِّ اغْفِرْ لِي” ក្នុងពេលអង្គុយចន្លោះស៊ូជោតទាំងពីរ។

៦. ដាក់ក្បាលស្មើនឹងខ្នងក្នុងពេលរូកុ។

៧. ញែកដើមដៃទាំងពីរចេញពីចំហៀងខ្លួន បើកពោះឲ្យឃ្លាតពីភ្លៅទាំងពីរ

ហើយភ្លៅទាំងពីរឲ្យឃ្លាតពីកំភួនជើងទាំងពីរក្នុងពេលស៊ូជោត។

៨. លើកកំភួនដៃទាំងពីរឲ្យផុតពីដីក្នុងពេលស៊ូជោត។

៩. អង្គុយលើបាតជើងឆ្វេង ហើយបញ្ឈរប្រអប់ជើងស្ដាំក្នុងពេលអង្គុយសូត្រតះយិតទីមួយ និងនៅពេលអង្គុយចន្លោះរវាងស៊ូជោតទាំងពីរ។

១០. អង្គុយដាក់គូទផ្ទាល់ដីនៅក្នុងតះយិតចុងក្រោយចំពោះសឡាតដែលមានបួនរ៉ក្អាត់ និងបីរ៉ក្អាត់ ដោយអង្គុយដាក់គូទលើដីស៊ីកប្រអប់ជើងឆ្វេងពីក្រោមជើងស្ដាំ ហើយបញ្ឈរប្រអប់ជើងស្ដាំ។

១១. ចង្អុលម្រាមដៃក្នុងពេលអង្គុយសូត្រតះយិតទីមួយ និងទីពីរ ចាប់តាំងពីពេលអង្គុយរហូតដល់បញ្ចប់ការសូត្រតះយិត និងកម្រើកម្រាមចង្អុលនោះក្នុងពេលបួងសួង(ឌូអា)។

១២. សឡាវ៉ាត និងសុំពរជ័យ(ហ្ពារ៉កាត់)ដល់ណាពីមូហាំម៉ាត់ និងក្រុមគ្រួសារណាពីមូហាំម៉ាត់ ព្រមទាំងទៅដល់ណាពីអ៊ីព្រហ៊ីម និងក្រុមគ្រួសារណាពីអ៊ីព្រហ៊ីមក្នុងតះយិតទីមួយ។

១៣. បួងសួងសុំទូអានៅក្នុងតះយិតចុងក្រោយ។

១៤. សូត្រឮៗក្នុងពេលសឡាតស៊ូពុស

សឡាតជុមអាត់ សឡាតរ៉យ៉ាទាំងពីរ សឡាតសុំទឹកភ្លៀង និងក្នុងពីររ៉ក្អាត់ដំបូងនៃសឡាតម៉ាហ្គ្រិប

និងសឡាតអ៊ីស្ហា។

១៥. សូត្រតិចៗក្នុងពេលសឡាតហ្ស៊ូហូរ

និងសឡាតអាសើរ ក៏ដូចជាក្នុងរ៉ក្អាត់ទីបីនៃសឡាតម៉ាហ្គ្រិប

និងពីររ៉ក្អាត់ចុងក្រោយនៃសឡាតអ៊ីស្ហា។

១៦.

សូត្រាស៊ូរ៉ោះ ឬអាយ៉ាត់ណាមួយនៃគម្ពីរគួរអានបន្ថែមពីលើការសូត្រស៊ូរ៉ោះ អាល់ហ្វាទីហះ

ព្រមទាំងយកចិត្តទុកដាក់លើប្រការដែលគួរគប្បីធ្វើ(ស៊ូណិត)ដែលនៅសល់ផ្សេងទៀតដែលមានក្នុងសឡាត

ក្រៅពីអ្វីដែលយើងបានលើកឡើងខាងលើ ក្នុងចំណោមនោះមានដូចជា៖ សូត្របន្ថែមទៅលើការសូត្រថា៖

“رَبَّنَا وَلَكَ الحَمْدُ” បន្ទាប់ពីងើបពីរូកុវិញ សម្រាប់អ៊ីម៉ាំម៉ាក់មុម

និងអ្នកសឡាតម្នាក់ឯង ព្រោះវាជាស៊ុណ្ណះ។ ហើយក្នុងចំណោមនោះផងដែរ

គឺការដាក់ដៃទាំងពីរនៅលើក្បាលជង្គង់ទាំងពីរដោយញែកម្រាមដៃចេញពីគ្នាក្នុងពេលរូកុ។

## មេរៀនទី១១៖

## ប្រការដែលនាំឲ្យខូចសឡាត

មានប្រាំបីប្រការ៖

១. និយាយស្តីដោយចេតនា និងដឹងច្បាស់(ថាជាប្រការដែលនាំឲ្យខូចសឡាត)។

ចំណែកអ្នកដែលភ្លេចភ្លាំង(អចេតនា) និងអ្នកដែលមិនដឹង នោះការសឡាតរបស់គេមិនខូចឡើយ។

២. ការសើច

៣. ការទទួលទានអាហារ

៤. ការផឹក

៥. លេចចេញកេរខ្មាស(អាវរ៉ាត់)

៦. ងាកចេញពីទិសគិបឡាត់ខ្លាំងពេក

៧. ធ្វើចលនាឥតប្រយោជន៍ច្រើនដងបន្តបន្ទាប់គ្នាក្នុងសឡាត

៨. បាត់បង់ភាពជ្រះស្អាត(ដាច់ទឹកវូហ្ពុ)

## មេរៀនទី១២៖ លក្ខខណ្ឌនៃវូហ្ពុ

មានដប់ប្រការ៖

ឥស្លាម

មានសតិបញ្ញា ចេះដឹងខុសត្រូវ
មានចេតនា(នៀត)
បន្តចេតនា(នៀត)យកវូហ្គុដោយមិនផ្លាស់ប្តូរចិត្ត
រហូតដល់ការយកវូហ្គុនោះបានចប់សព្វគ្រប់
ដាច់ស្រឡះពីប្រការដែលតម្រូវឱ្យយកវូហ្គុ
សម្អាតទ្វារមុខនិងទ្វារក្រោយដោយទឹក
ឬដោយការកិតជាមុន(ប្រសិនបើបានបត់ជើង)
ភាពជ្រះស្អាតនៃទឹកដែលប្រើសម្រាប់ការយកវូហ្គុនោះ
និងភាពស្របច្បាប់ក្នុងការប្រើប្រាស់ទឹកនោះ
ជម្រះចេញនូវអ្វីដែលរារាំងទឹកមិនឱ្យជ្រាបដល់ស្បែក
ហើយនិងការចូលពេលវេលាសឡាតចំពោះអ្នកដែលមានបញ្ហាដាច់វូហ្គុជាប្រចាំ។

## មេរៀនទី១៣៖

## កាតព្វកិច្ចនៃវូហ្គុ

មានប្រាំមួយប្រការ៖
លាងមុខ
រួមបញ្ចូលទាំងការខ្ពុរមាត់ បឺតទឹកចូលច្រមុះហើយបញ្ចេញមកវិញ
លាងដៃទាំងពីររហូតដល់កែងដៃ
ជូតក្បាលទាំងមូល
រួមបញ្ចូលទាំងស្លឹកត្រចៀកទាំងពីរ
លាងជើងទាំងពីររហូតដល់ភ្នែកគោល

អនុវត្តតាមលំដាប់លំដោយ និងធ្វើជាបន្តបន្ទាប់គ្នា។ គប្បីលាងមុខ ដៃទាំងពីរ និងជើងទាំងពីរចំនួនបីដង។ ក៏ដូចគ្នាដែរចំពោះការខ្ពុរមាត់ និងបឺតទឹកចូលច្រមុះ។ ប៉ុន្តែដែលចាំបាច់ដាច់ខាតនោះ គឺត្រឹមតែមួយដងប៉ុណ្ណោះ។ ចំណែកឯការជូតក្បាលវិញ គឺមិនគប្បីជូតច្រើនដងឡើយ ដូចដែលមានបញ្ជាក់នៅក្នុងហាទីស្ហត្រឹមត្រូវ(សហេស)ជាច្រើន។

## មេរៀនទី១៤៖ ប្រការដែលនាំឲ្យដាច់ ឬខូចវូហ្ទុ

មានប្រាំមួយប្រការ៖

មានអ្វីចេញពីទ្វារទាំងពីរ(ទ្វារមុខ និងទ្វារក្រោយ)

មានភាពកខ្វក់(ណាជិស)ចេញពីរាងកាយ(ក្រៅពីតាមទ្វារទាំងពីរ)ក្នុងបរិមាណយ៉ាងច្រើន

បាត់បង់ស្មារតីដោយសារការដេកលក់ ឬដោយប្រការផ្សេងៗ ប៉ះកេរខ្មាសដោយដៃផ្ទាល់ដោយគ្មានទ្រនាប់

មិនថាទ្វារមុខ ឬទ្វារក្រោយ បរិភោគសាច់អូដ្ឋ និងការរបូតចេញពីសាសនាអ៊ីស្លាម(មូរតាត់)។

សូមអល់ឡោះមេត្តាការពារពួកយើង និងអ្នកមូស្លីមទាំងឡាយឱ្យរួចផុតពីទង្វើបែបនេះផងចុះ។

ចំណុចសំខាន់៖

ចំពោះការងូតទឹកឲ្យសព យោងតាមទស្សនៈដែលត្រឹមត្រូវ គឺមិនធ្វើឲ្យខូចវូហ្ទុឡើយ

ហើយនេះគឺជាទស្សនៈរបស់សាសនវិទូឥស្លាមភាគច្រើន ដោយសារតែគ្មានភស្តុតាងបញ្ជាក់បែបនេះ។ ក៏ប៉ុន្តែប្រសិនបើដៃអ្នកដែលងូតទឹកឲ្យសពប៉ះចំប្រដាប់ភេទសពដោយគ្មានទ្រនាប់

គឺចាំបាច់ត្រូវយកវូហ្ទុ។

ទោះជាយ៉ាងណា ចាំបាច់លើអ្នកដែលងូតទឹកឲ្យសព

គឺមិនត្រូវប៉ះប្រដាប់ភេទសពឡើយ លើកលែងតែមានអ្វីទ្រាប់។ ក៏ដូចគ្នាដែរ ការប៉ះស្ត្រី

គឺមិនធ្វើឱ្យខូចវូហ្ទុឡើយ ទោះបីជាការប៉ះនោះជាការប៉ះដោយមានចំណង់តណ្ហា ឬគ្មានចំណង់តណ្ហាក៏ដោយ

យោងតាមទស្សនៈដែលត្រឹមត្រូវជាងគេក្នុងចំណោមទស្សនៈទាំងពីររបស់សាសនវិទូអ៊ីស្លាម

ដរាបណាមិនមានអ្វីមួយចេញពីខ្លួនអ្នកដែលប៉ះទេនោះ ព្រោះណាពី ﷺ លោកបានថើបភរិយាមួយចំនួនរបស់លោក។

បន្ទាប់មក
លោកបានសឡាតដោយមិនបានយកវូហ្ទុឡើយ។
ចំណែកឯបន្ទូលរបស់អល់ឡោះជាម្ចាស់នៅក្នុងស៊ូរ៉េាះ
អាន់នីសាក និងស៊ូរ៉េាះ អាល់ម៉ាអ៊ីហ្ទះ៖

﴿...أَوۡ لَٰمَسۡتُمُ ٱلنِّسَآءَ...﴾

"...ឬប៉ះពាល់ស្រ្តី..." [គម្ពីរគួរអាន ៤:៤៣] [គម្ពីរគួរអាន ៥:៦] អត្ថន័យរបស់វាគឺសំដៅលើការរួមមេត្រី

យោងតាមទស្សនៈដែលត្រឹមត្រូវជាងគេក្នុងចំណោមទស្សនៈទាំងពីររបស់សាសនវិទូអ៊ីស្លាម ហើយវាក៏ជាទស្សនៈរបស់អ៊ិពនូអាប់ហ្ពាស رضي الله عنهما ក៏ដូចជាក្រុមអ្នកប្រាជ្ញឥស្លាមទាំងជំនាន់មុន និងជំនាន់ក្រោយផងដែរ។ ហើយអល់ឡោះ គឺជាម្ចាស់នៃការចង្អុលបង្ហាញ។

## មេរៀនទី១៥៖ ប្រកាន់ខ្ជាប់នឹងចរិតលក្ខណៈឥស្លាមសម្រាប់អ្នកមូស្លីមគ្រប់រូប

ក្នុងចំណោមនោះមានដូចជា

ភាពទៀងត្រង់ រក្សាទំនុកចិត្ត រក្សាភាពបរិសុទ្ធ ភាពអៀនខ្មាស ភាពក្លាហាន

ចិត្តសប្បុរស គោរពពាក្យសន្យា រក្សាខ្លួនឲ្យស្អាតស្អំពីរាល់ប្រការទាំងឡាយដែលអល់ឡោះជាម្ចាស់ទ្រង់បានហាមឃាត់

ធ្វើល្អជាមួយអ្នកជិតខាង

ជួយដល់អ្នកដែលមានតម្រូវការទៅតាមលទ្ធភាព ក៏ដូចជាចរិតលក្ខណៈផ្សេងៗទៀតដែលគម្ពីគួរអាន

ឬស៊ុណ្ណៈបានចង្អុលបង្ហាញ។

## មេរៀនទី១៦៖ ប្រកាន់ខ្ជាប់នឹងសុជីវធម៌ឥស្លាម

ក្នុងចំណោមនោះមានដូចជា

ការឲ្យសាឡាម(គារវកិច្ច) ទឹកមុខញញឹមរាក់ទាក់ ទទួលទានអាហារ និងផឹកដោយដៃស្តាំ ពោលព្រះនាមអល់ឡោះ(សូត្រ

بسم الله)នៅពេលចាប់ផ្តើម ហើយថ្លែងសរសើរដល់អល់ឡោះ(សូត្រ الحمد لله)នៅពេលបញ្ចប់ ថ្លែងសរសើរដល់អល់ឡោះ(សូត្រ الحمد لله)បន្ទាប់ពីកណ្តាស ឆ្លើយតបចំពោះអ្នកកណ្តាស(ដោយសូត្រថា៖

يرحمك الله) ប្រសិនបើអ្នកកណ្តាសនោះបានសរសើរតម្កើងដល់អល់ឡោះ

សួរសុខទុក្ខអ្នកជំងឺ

ចូលរួមដង្ហែរសពទៅកាន់កន្លែងសឡាត និងទៅកាន់កន្លែងបញ្ចុះ

ប្រកាន់ខ្ជាប់នឹងសុជីវធម៌ឥស្លាមនៅពេលចូលម៉ាស្ជិត

ឬចូលផ្ទះ និងពេលចេញមកវិញ ក៏ដូចជានៅពេលធ្វើដំណើរ ប្រកាន់ខ្ជាប់នឹងសុជីវធម៌ចំពោះមាតាបិតា

សាច់ញាតិ អ្នកជិតខាង មនុស្សចាស់ និងក្មេងៗ ចូមរួមអបអរសាទរចំពោះទារកទើបនឹងកើត ជូនពរដល់គូស្វាមីភរិយាថ្មី

ចូលរួមរំលែកទុក្ខចំពោះអ្នកជួបទុក្ខសោក ក៏ដូចជាសុជីវធម៌ឥស្លាមផ្សេងៗទៀតនៅក្នុងការស្លៀកពាក់

ពេលដោះសម្លៀកបំពាក់ និងពេលពាក់ស្បែកជើង។

## មេរៀនទី១៧៖ ព្រមានពីប្រការស្ទីរិក និងអំពើបាបគ្រប់ប្រភេទ

ក្នុងចំណោមនោះមានដូចជា

ប្រាំពីរប្រការដែលនាំឲ្យអន្តរាយ គឺការធ្វើស្ទីរិកចំពោះអល់ឡោះ ប្រើអំពើមន្តអាគម

សម្លាប់ជីវិតដែលអល់ឡោះហាមឃាត់ លើកលែងតែដោយស្របច្បាប់ ស៊ីការប្រាក់ ស៊ីទ្រព្យសម្បត្តិក្មេងកំព្រា

រត់ចោលសមរភូមិក្នុងពេលជួបសត្រូវ និងការចោទប្រកាន់ស្ត្រីមានជំនឿដែលស្អាតស្អំ

បរិសុទ្ធថាប្រព្រឹត្តអំពើហ្ស៊ីណា។

ហើយក្នុងចំណោមនោះផងដែររួមមាន

ការអកតញ្ញូចំពោះឪពុកម្ដាយ កាត់ផ្ដាច់ចំណងសាច់សាលោហិត ធ្វើសាក្សីក្លែងក្លាយ ស្បថបំពាន

ធ្វើបាបអ្នកជិតខាង បំពានលើអាយុជីវិត ទ្រព្យសម្បត្តិ និងកិត្តិយសអ្នកដទៃ សេពគ្រឿងស្រវឹង លេងល្បែងស៊ីសង និយាយដើមគេ ញុះញង់អ្នកដទៃ ក៏ដូចជាប្រការផ្សេងៗទៀតដែលអល់ឡោះជាម្ចាស់ ឬអ្នកនាំសាររបស់ទ្រង់ ﷺ បានហាមឃាត់។

## មេរៀនទី១៨៖ ការរៀបចំសព សឡាតឲ្យសព និងបញ្ចុះសព

ការបកស្រាយលម្អិតមានដូចតទៅ៖

ទីមួយ៖ ច្បាប់បង្គាប់ប្រើឱ្យបង្រៀនអ្នកហៀបនឹងស្លាប់ឱ្យពោលពាក្យ៖ “لَا إِلَٰهَ إِلَّا اللَّهُ” (គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ) ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«لَقِّنُوا مَوْتَاكُمْ: لَا إِلَٰهَ إِلَّا اللَّهُ»[7]

“ចូរបង្រៀនអ្នកស្លាប់នៃពួកអ្នកនូវពាក្យ

៖ “لَا إِلَهَ إِلَّا اللَّهُ” (គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ)”។[1] រាយការណ៍ដោយ មូស្លីម ក្នុងសៀវភៅសហេសរបស់គាត់។ ពាក្យថា “អ្នកស្លាប់” ក្នុងហាទីស្ហនេះ គឺសំដៅលើអ្នកដែលហៀបនឹងស្លាប់ ពោលគឺអ្នកដែលសញ្ញានៃសេចក្ដីស្លាប់បានលេចឡើងចំពោះពួកគេ។

ទីពីរ៖ នៅពេលដែលប្រាកដថា បុគ្គលនោះបានស្លាប់ហើយ គេត្រូវបំបិទភ្នែកសព និងចងចង្កាសព(ដើម្បីកុំឲ្យមាត់សពចំហ) ព្រោះមានភស្តុតាងពីស៊ុណ្ណះដែលបញ្ជាក់បែបនេះ។

ទីបី៖ ចាំបាច់ងូតទឹកឲ្យសពអ្នកស្លាប់ដែលជាមូស្លីម លើកលែងតែសពនោះជាអ្នកពលី(ស្ហាហ៊ីទ)ដែលបានស្លាប់ក្នុងសមរភូមិ គឺមិនត្រូវងូតទឹកឲ្យសពនោះឡើយ ហើយក៏មិនត្រូវសឡាតឲ្យសពនោះដែរ។ ផ្ទុយទៅវិញ គឺត្រូវបញ្ចុះសពបុគ្គលនោះទាំងសម្លៀកបំពាក់របស់គេ ព្រោះណាពី ﷺ លោកមិនងូតទឹកឲ្យ និងមិនបានសឡាតឲ្យសពអ្នកដែលបានពលីក្នុងសមរភូមិអ៊ូហ៊ុទឡើយ។

[1] រាយការណ៍ដោយ មូស្លីម:៩១៦-៩១៧

ត្រូវបិទបាំងកេរខ្មាសរបស់សព។
បន្ទាប់មក លើកសពឡើងខ្ពស់បន្តិច
ហើយសង្កត់ពោះសពថ្នមៗ។ បន្ទាប់មក
អ្នកងូតទឹកឲ្យសពត្រូវយកក្រណាត់
ឬអ្វីដែលស្រដៀងគ្នានេះមកពាក់ដៃ
រួចលាងសម្អាតកេរខ្មាសសព។ បន្ទាប់មកទៀត
ត្រូវយកវូហ្ទុឲ្យសពដូចដែលគេយកវូហ្ទុដើម្បីសឡា
ត។ ក្រោយមក ត្រូវលាងក្បាល
និងពុកចង្ការរបស់សពដោយទឹកដែលលាយនឹង
ស្លឹកពុទ្រា ឬអ្វីដែលស្រដៀងគ្នានេះ។
បន្ទាប់មកទៀត
ត្រូវលាងចំហៀងខ្លួនខាងស្តាំនៃសព
រួចបន្តទៅចំហៀងខ្លួនខាងឆ្វេង។
ក្រោយមកទៀត
គេត្រូវងូតទឹកឲ្យសពតាមរបៀបនេះជាលើកទីពី
រ
និងលើកទីបីទៀត ដោយរាល់ៗលើក
ត្រូវយកដៃសង្កត់ពោះសពថ្នមៗ។

**ប្រសិនបើមានអ្វីមួយចេញពីខ្លួនសព(ដូចជាកាកសំណល់) ត្រូវលាងសម្អាតវាចេញ ហើយត្រូវទប់កន្លែងនោះដោយដុំសំឡី ឬរបស់ដែលស្រដៀងគ្នានេះដើម្បីកុំឲ្យវាចេញមកទៀត។ ប្រសិនបើនៅតែមិនអាចទប់ជាប់(នៅតែហូរមកទៀត) គឺត្រូវប្រើដីឥដ្ឋស្អាត ឬមធ្យោបាយវេជ្ជសាស្ត្រទំនើប ដូចជាបង់ស្អិត ឬអ្វីដែលស្រដៀងគ្នានេះ។**

ហើយត្រូវយកវូហ្ឍុឱ្យសពម្តងទៀត។ ប្រសិនបើងូតទឹកចំនួនបីដងហើយ តែសពនៅតែមិនទាន់ស្អាតទៀត គេត្រូវបន្ថែមដល់ប្រាំដង ឬដល់ប្រាំពីរដង។ បន្ទាប់មក ត្រូវជូតសម្អាតខ្លួនសពឱ្យស្ងួតដោយក្រណាត់ ហើយត្រូវលាបគ្រឿងក្រអូបនៅតាមគន្លាក់នានានៃរាងកាយសព និងត្រង់កន្លែងដែលប៉ះដីពេលស៊ូជោត។ ប្រសិនបើលាបគ្រឿងក្រអូបសព្វទាំងខ្លួនប្រាណសពតែម្តង គឺកាន់តែប្រសើរ។ ត្រូវចំហុយ ឬឆ្អុងក្រណាត់រុំសព(កាហ្វាន់)ដោយផ្សែងក្រអូប។

ហើយប្រសិនបើពុកមាត់ ឬក្រចករបស់សពវែង អាចកាត់តម្រឹមបាន ប៉ុន្តែបើទុកចោលមិនកាត់ ក៏គ្មានបញ្ហាអ្វីដែរ។ មិនត្រូវសិតសក់ មិនត្រូវកោររោមប្រដាប់ភេទ និងមិនត្រូវកាត់ស្បែកចុងលិង្គ(ខតាន់)ឲ្យសពឡើយ ព្រោះគ្មានភស្តុតាងបញ្ជាក់បែបនេះនោះទេ។ ហើយប្រសិនបើសពនោះជាស្ត្រី គេត្រូវក្រងសក់សពនោះជាបីកម្រង ហើយទម្លាក់សក់នោះទៅផ្នែកខាងក្រោយ។

ទីប្រាំ៖ ការរុំសព(កាហ្វាន់)

ចំពោះបុរស ជាការប្រសើរបំផុត គឺត្រូវរុំសពជាមួយនឹងក្រណាត់សបីផ្ទាំងដោយមិនមានអាវ និងឈ្នួតក្បាល(សាល់)ឡើយ ដូចដែលគេបានអនុវត្តចំពោះសពណាពី ﷺ ដោយយកក្រណាត់នោះមករុំត្រួតពីលើគ្នា។ តែប្រសិនបើគេរុំសពជាមួយនឹងអាវ(ផ្នែកខាងលើ) ក្រណាត់សំពត់(ផ្នែកខាងក្រោម) និងក្រណាត់មួយផ្ទាំងទៀតរុំពីលើ ក៏មិនមានទាស់ខុសអ្វីដែរ។

ចំណែកសពស្ត្រីវិញ គឺត្រូវរុំដោយក្រណាត់ប្រាំផ្ទាំង គឺអាវ(ផ្នែកខាងលើ) កន្សែងរុំក្បាល សំពត់(ផ្នែកខាងក្រោម) និងក្រណាត់ពីរផ្ទាំងទៀតរុំពីលើ។

ចំពោះសពក្មេងប្រុស
គឺត្រូវរុំដោយក្រណាត់ពីមួយផ្ទាំង ទៅបីផ្ទាំង។
រីឯក្មេងស្រីវិញ គឺត្រូវរុំដោយអាវមួយផ្ទាំង
និងក្រណាត់ពីរផ្ទាំងទៀតរុំពីលើ។
កាតព្វកិច្ច(យ៉ាងហោចបំផុត)ចំពោះសពគ្រប់រូប
គឺត្រូវរុំដោយក្រណាត់មួយផ្ទាំងដែលអាចបិទបាំងរាងកាយសពទាំងមូលបាន។
តែប្រសិនបើសពនោះជាអ្នកដែលស្ថិតក្នុងតំណមអៀហរ៉ម
គេត្រូវងូតទឹកសម្អាតសពដោយទឹកលាយនឹងស្លឹកពុទ្រា
ហើយត្រូវរុំដោយសម្លៀកបំពាក់អៀហរ៉មរបស់សពនោះតែម្តង
ឬដោយក្រណាត់ផ្សេងពីនេះក៏បាន។
ប៉ុន្តែមិនត្រូវគ្របក្បាល និងមុខរបស់សពឡើយ
ហើយក៏មិនត្រូវប្រើគ្រឿងក្រអូបលើសពនោះដែរ
ពីព្រោះសពនោះនឹងត្រូវគេប្រោសឲ្យរស់ឡើងវិញនៅថ្ងៃបរលោក
ក្នុងនាមជាអ្នកដែលស្ថិតក្នុងតំណមអៀហរ៉ម
ដូចដែលមានភស្តុតាងបញ្ជាក់នៅក្នុងហាទីស្ហត្រឹមត្រូវពីរ៉ស៊ូលុលឡោះ
ﷺ ។
ប្រសិនបើសពដែលស្លាប់ក្នុងតំណមអៀហរ៉មនោះជាស្ត្រីវិញ

គឺត្រូវរុំសពរបស់នាងដូចស្ត្រីដទៃទៀតដែរ ប៉ុន្តែមិនត្រូវប្រើគ្រឿងក្រអូបលើសពឡើយ ហើយក៏មិនត្រូវគ្របមុខរបស់សពដោយស្បៃគ្របមុខ(នីកប)

និងគ្របដៃទាំងពីររបស់សពដោយស្រោមដៃនោះដែរ។ ផ្ទុយទៅវិញ ត្រូវគ្របមុខ

និងដៃទាំងពីររបស់សពនោះនឹងក្រណាត់រុំសពដែលគេបានរុំនាង

ដូចដែលបានរៀបរាប់រួចមកហើយអំពីរបៀបរុំសពស្ត្រី។

ទីប្រាំមួយៈ

អ្នកដែលមានសិទ្ធិជាងគេនៅក្នុងការងូតទឹកឲ្យសព សឡាតឲ្យសព និងបញ្ចុះសព

គឺអ្នកដែលសពបានផ្តែផ្តាំ(មុនពេលស្លាប់)ឲ្យចាត់ចែងលើកិច្ចការនេះ។

ក្រោយមក គឺឪពុក(របស់សព)។ បន្ទាប់មក គឺជីតា។ បន្ទាប់មកទៀត គឺអ្នកដែលជាប់សាច់ឈាមនឹងសពជាងគេជាបន្តបន្ទាប់ជាបុរសតាមលំដាប់

ក្នុងករណីដែលសពនោះជាបុរស។

ចំណែកឯអ្នកដែលមានសិទ្ធិអាទិភាពជាងគេក្នុងការងូតទឹកសពស្ត្រី

គឺអ្នកដែលសពបានផ្តែផ្តាំ(មុនពេលស្លាប់)ឲ្យចាត់ចែងលើកិច្ចការនេះ។ ក្រោយមក គឺម្តាយ(របស់សព)។

បន្ទាប់មក គឺជីដូន។ បន្ទាប់មកទៀត គឺអ្នកដែលជាប់សាច់ឈាមនឹងសពជាងគេជាបន្តបន្ទាប់ជាស្ត្រីតាមលំដាប់

។ ចំពោះប្តីប្រពន្ធវិញ គឺអាចងូតទឹកឲ្យគ្នាបានដោយសារ(សពអាពូហ្គាកើរ)អាស៊្សិទ្ទីក رضي الله عنه ត្រូវបានភរិយារបស់គាត់ងូតទឹកឲ្យ ហើយអាលី رضي الله عنه ក៏បានងូតទឹកឲ្យ(សព)ភរិយារបស់គាត់ហ្វាទីម៉ះ رضي الله عنها ផងដែរ។

ទីប្រាំពីរ៖ របៀបសឡាតឲ្យសព

ត្រូវតឹកពៀរចំនួនបួនដង។

បន្ទាប់ពីតឹកពៀរលើកទីមួយ ត្រូវសូត្រស៊ូរ៉ោះអាល់ហ្វាទីហះ។ ប្រសិនបើគេសូត្រស៊ូរ៉ោះខ្លីមួយ

ឬសូត្រមួយអាយ៉ាត់ ពីរអាយ៉ាត់បន្ថែមទៀត នោះជាការប្រសើរ

យោងតាមហាទីស្ហត្រឹមត្រូវ(សហេស)ដែលបានបញ្ជាក់បែបនេះពី

អ៊ិពនូអាប់ហ្គាស رضي الله عنهما

។ បន្ទាប់មក ត្រូវតឹកពៀរលើកទីពីរ ហើយសឡាវ៉ាតលើណាពី ﷺ

ដូចការសឡាវ៉ាតនៅក្នុងតះយិតដែរ។

បន្ទាប់មកទៀត

ត្រូវតឹកពៀរជាលើកទីបី ហើយសូត្រថា៖ "اللَّهُمَّ

اغْفِرْ لِحَيِّنَا وَمَيِّتِنَا، وَشَاهِدِنَا وَغَائِبِنَا، وَصَغِيرِنَا وَكَبِيرِنَا، وَذَكَرِنَا وَأُنْثَانَا، اللَّهُمَّ مَنْ أَحْيَيْتَهُ مِنَّا فَأَحْيِهِ عَلَى الْإِسْلَامِ، وَمَنْ تَوَفَّيْتَهُ مِنَّا ،فَتَوَفَّهُ عَلَى الْإِيمَانِ، اللَّهُمَّ اغْفِرْ لَهُ، وَارْحَمْهُ، وَعَافِهِ، وَاعْفُ عَنْهُ وَأَكْرِمْ نُزُلَهُ، وَوَسِّعْ مُدْخَلَهُ، وَاغْسِلْهُ بِالْمَاءِ وَالثَّلْجِ وَالْبَرَدِ، وَنَقِّهِ مِنَ الْخَطَايَا

كَمَا يُنَقَّى الثَّوْبُ الْأَبْيَضُ مِنَ الدَّنَسِ، وَأَبْدِلْهُ دَارًا خَيْرًا مِنْ دَارِهِ، وَأَهْلًا خَيْرًا مِنْ أَهْلِهِ، وَأَدْخِلْهُ الْجَنَّةَ، وَأَعِذْهُ مِنْ عَذَابِ الْقَبْرِ، وَعَذَابِ النَّارِ، وَافْسَحْ لَهُ فِي قَبْرِهِ، وَنَوِّرْ لَهُ فِيهِ، اللَّهُمَّ لَا تَحْرِمْنَا أَجْرَهُ وَلَا تُضِلَّنَا بَعْدَهُ"

(ឱអល់ឡោះជាម្ចាស់!

សូមទ្រង់មេត្តាអភ័យទោសដល់អ្នកដែលនៅរស់ និងអ្នកដែលបានស្លាប់នៃពួកយើងផង ទាំងអ្នកមានវត្តមាន

ទាំងអ្នកអវត្តមាន ទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី។ ឱអល់ឡោះជាម្ចាស់! ជនណាដែលទ្រង់ឲ្យគេមានជីវិតរស់នៅក្នុងចំណោមពួកយើង

សូមទ្រង់ឱ្យគេមានជីវិតរស់នៅលើសាសនាឥស្លាមផង។ ហើយជនណាដែលទ្រង់ឱ្យគេស្លាប់ទៅក្នុងចំណោមពួកយើង

សូមទ្រង់ឱ្យគេស្លាប់នៅលើសេចក្តីជំនឿ(អ៊ីម៉ាន)ផង។ ឱអល់ឡោះជាម្ចាស់! សូមទ្រង់មេត្តាអភ័យទោសឲ្យគាត់

មេត្តាករុណាដល់គាត់ ផ្តល់ភាពសុខសាន្តដល់គាត់ និងលើកលែងទោសឲ្យគាត់ផង។
សូមទ្រង់ផ្តល់កិត្តិយសដល់កន្លែងស្នាក់នៅរបស់គាត់ និងពង្រីកច្រកចូលរបស់គាត់ឱ្យបានធំទូលាយផង។ សូមទ្រង់មេត្តាលាងសម្អាតគាត់ដោយទឹក ទឹកកក
និងព្រិល
ហើយសូមជម្រះគាត់ពីកំហុសឆ្គង(បាបកម្ម)ទាំងឡាយ
ដូចដែលគេជម្រះសម្អាតសម្លៀកបំពាក់ពណ៌សពីភាពកខ្វក់ដូច្នោះដែរ។
សូមទ្រង់ប្តូរឲ្យគាត់នូវផ្ទះមួយដែលប្រសើរជាងផ្ទះ(ចាស់)របស់គាត់,
ក្រុមគ្រួសារដែលប្រសើរជាងក្រុមគ្រួសាររបស់គាត់ និងភរិយាដែលប្រសើរជាងភរិយារបស់គាត់។
ហើយសូមទ្រង់បញ្ចូលគាត់ទៅក្នុងឋានសួគ៌ ព្រមទាំងការពារគាត់ពីទណ្ឌកម្មក្នុងផ្នូរ និងទណ្ឌកម្មនៃភ្លើងនរកផង។
សូមទ្រង់មេត្តាពង្រីកផ្នូររបស់គាត់ឲ្យបានធំទូលាយសម្រាប់គាត់
និងសូមឲ្យមានពន្លឺសម្រាប់គាត់នៅក្នុងផ្នូរនោះផង។ ឱអល់ឡោះជាម្ចាស់!
សូមទ្រង់កុំរារាំងពួកយើងពីផលបុណ្យរបស់គាត់

ហើយសូមទ្រង់កុំធ្វើឱ្យពួកយើងវង្វេងបន្ទាប់ពី(ការបាត់បង់)គាត់)។ បន្ទាប់មកទៀត ត្រូវតឹកពៀរលើកទីបួន

រួចឲ្យសាឡាមទៅខាងស្តាំតែមួយដងប៉ុណ្ណោះ។

ស៊ូណិតគប្បីលើកដៃទាំងពីរនៅរាល់ពេលតឹកពៀរ។

ប្រសិនបើសពជាស្ត្រី គេត្រូវសូត្រថាៈ (اللَّهم اغفِر لها ...) រហូតដល់ចប់។ ប្រសិនបើសពមានពីរនាក់

គេត្រូវសូត្រថាៈ (اللَّهُم اغفِر لهما ...) រហូតដល់ចប់។ ហើយប្រសិនបើសពមានច្រើនជាងនេះ

គេត្រូវប្រើទម្រង់ពហុវចនៈ ដោយសូត្រថាៈ (اللَّهُم اغفِر لهم ...) រហូតដល់ចប់។ តែប្រសិនបើសពនោះជាកូនក្មេងវិញ

គេត្រូវសូត្របែបនេះថាៈ "اللَّهُمَّ

اجْعَلْهُ فَرَطًا وَذُخْرًا لِوَالِدَيْهِ، وَشَفِيعًا مُجَابًا، اللَّهُمَّ ثَقِّلْ بِهِ مَوَازِينَهُمَا، وَأَعْظِمْ بِهِ أُجُورَهُمَا، وَأَلْحِقْهُ بِصَالِحِ سَلَفِ الْمُؤْمِنِينَ، وَاجْعَلْهُ فِي كَفَالَةِ إِبْرَاهِيمَ عَلَيْهِ الصَّلَاةُ وَالسَّلَامُ، وَقِهِ بِرَحْمَتِكَ عَذَابَ الْجَحِيمِ"

(ឱអល់ឡោះជាម្ចាស់!

សូមទ្រង់មេត្តាធ្វើឱ្យក្មេងនេះក្លាយជាអ្នកនាំមុខ

និងជាទ្រព្យសន្សំសម្រាប់ឪពុកម្តាយរបស់គេ ព្រមទាំងជាអ្នកជួយអន្តរាគមន៍ដែលត្រូវបានគេ(អល់ឡោះ)ទទួលយកផង។

ឱអល់ឡោះជាម្ចាស់!
សូមទ្រង់មេត្តាធ្វើឱ្យជញ្ជីង(ថ្លឹងអំពើល្អ)របស់ឪពុកម្តាយក្មេងនេះមានទម្ងន់ធ្ងន់ដោយសារគេ
និងសូមទ្រង់បង្កើនផលបុណ្យរបស់គាត់ទាំងពីរដោយសារគេផង។
សូមទ្រង់មេត្តាភ្ជាប់ក្មេងនេះជាមួយនឹងកុសលបុគ្គលជំនាន់មុននៃអ្នកមានជំនឿទាំងឡាយ
ហើយសូមទ្រង់មេត្តាដាក់រូបគេឱ្យស្ថិតក្រោមការបីបាច់ថែរក្សារបស់អ៊ីព្រហ៊ីម عليه السلام ព្រមទាំងការពាររូបគេពីទណ្ឌកម្មនៃភ្លើងនរកដោយក្តីមេត្តាករុណារបស់ទ្រង់ផង)។
តាមស៊ុណ្ណះ អ៊ីម៉ាំត្រូវឈរនៅត្រង់ផ្នែកក្បាល
ប្រសិនបើសពជាបុរស
ហើយឈរនៅត្រង់ចង្កេះ(ពាក់កណ្តាលខ្លួន) ប្រសិនបើសពជាស្ត្រី។
ប្រសិនបើសពមានច្រើន(មានប្រុស
មានស្រី) គឺសពបុរសត្រូវដាក់នៅជាប់នឹងអ៊ីម៉ាំ។
ចំណែកឯសពស្ត្រីត្រូវដាក់នៅខាងទិសគិបឡាត់(បន្ទាប់ពីសពបុរស)។ ប្រសិនបើមានសពក្មេងៗផងដែរ
នោះសពក្មេងប្រុសត្រូវដាក់មុនសពស្ត្រី។
បន្ទាប់មក ទើបសពស្ត្រី ហើយបន្ទាប់មកទៀត ទើបសពក្មេងស្រី។
ក្បាលរបស់សពក្មេងប្រុសត្រូវដាក់ឲ្យស្មើនឹងក្បាលរបស់សពបុរស។

រីឯផ្នែកកណ្តាល(ចង្កេះ)របស់សពស្ត្រីត្រូវដាក់ឲ្យស្មើនឹងក្បាលរបស់សពបុរស។

ដូចគ្នានេះដែរ ចំពោះសពក្មេងស្រី ក្បាលរបស់នាងត្រូវដាក់ឲ្យស្មើនឹងក្បាលរបស់សពស្ត្រី

ហើយផ្នែកកណ្តាល(ចង្កេះ)របស់នាងត្រូវដាក់ឲ្យស្មើនឹងក្បាលរបស់សពបុរស។

អ្នកចូលរួមសឡាតទាំងអស់ត្រូវឈរនៅពីក្រោយអ៊ីមុាំ

លើកលែងក្នុងករណីនៅសល់មនុស្សតែម្នាក់គត់ដែលរកកន្លែងឈរនៅពីក្រោយអ៊ីមុាំមិនបាន

នោះគេត្រូវឈរនៅខាងស្តាំដៃអ៊ីមុាំ។

ទីប្រាំបី៖ របៀបបញ្ចុះសព

ច្បាប់បង្គាប់ប្រើឲ្យជីកផ្នូរឱ្យបានជ្រៅជម្រៅពាក់កណ្តាលខ្លួនមនុស្សប្រុស

ហើយត្រូវធ្វើលៀងហាត់នៅផ្នែកខាងគិបឡាត់។

ត្រូវដាក់សពក្នុងលៀងហាត់ដោយដាក់ផ្អៀងទៅខាងស្តាំ។

ត្រូវស្រាយចំណងក្រណាត់រុំសពចេញ ដោយគ្រាន់តែស្រាយបានហើយ មិនបាច់ទាញចេញទេ

ពោលគឺត្រូវទុកនៅទីនោះ។

មិនត្រូវបើកមុខសពឡើយ ទោះបីជាសពនោះជាបុរស ឬស្ត្រីក៏ដោយ។

បន្ទាប់មក ត្រូវដាក់ដីឥដ្ឋគ្របពីលើ(លៀងហាត់) ហើយបិទចន្លោះប្រហោងដោយដីភក់ដើម្បីឱ្យវាជាប់មាំ

និងដើម្បីកុំឱ្យដីធ្លាក់សង្កត់លើសព។ ប្រសិនបើគ្មានដីឥដ្ឋទេ គេអាចប្រើប្រាស់អ្វីផ្សេងទៀត ដូចជាបន្ទះក្តារ ឬដុំថ្ម ឬឈើ ដើម្បីការពារកុំឱ្យដីធ្លាក់សង្កត់លើសព។ បន្ទាប់មក ត្រូវចាក់ដីលុបពីលើ។ នៅពេលនោះ ស៊ុណិតឱ្យសូត្រថា៖ « بِسْمِ اللهِ وعلى مِلَّةِ رَسولِ اللهِ»។

គេអាចលើកផ្នូរឱ្យខ្ពស់ត្រឹមប្រហែលមួយចំអាម ហើយត្រូវរាយគ្រួសពីលើផ្នូរប្រសិនបើអាចធ្វើទៅបាន និងប្រោះទឹកពីលើ។

ហើយច្បាប់បង្គាប់ប្រើចំពោះអ្នកដែលចូលរួមដង្ហែរសពឱ្យឈរនៅក្បែរផ្នូរ ហើយបួងសួងសុំទូអាឲ្យសព ព្រោះណាពី ﷺ កាលណាលោករួចរាល់ពីការបញ្ចុះសព លោកតែងឈរនៅក្បែរផ្នូរ ហើយបានមានប្រសាសន៍ថា៖

«اسْتَغْفِرُوا لِأَخِيكُمْ، وَاسْأَلُوا لَهُ التَّثْبِيتَ، فَإِنَّهُ الْآنَ يُسْأَلُ»[8].

«ចូរពួកអ្នកសុំការអភ័យទោសឱ្យបងប្អូនរបស់ពួកអ្នក ហើយចូរសុំឲ្យគាត់មានភាពនឹងនរផង ព្រោះថាពិតណាស់ ពេលនេះ គាត់កំពុងត្រូវបានគេសួរហើយ»។[1]

---

[1] រាយការណ៍ដោយ អាពូហ្ទាវូទ:៣២២១

ទីប្រាំបួនៈ
ចំពោះអ្នកដែលមិនទាន់បានសឡាតឲ្យសព
គឺគេអាចសឡាតឲ្យសពបានបន្ទាប់ពីបញ្ចុះសពរួច
ព្រោះណាពី ﷺ លោកបានធ្វើដូច្នេះ។
នេះក្នុងករណីដែលសពនោះត្រូវបានបញ្ចុះក្នុងអំឡុងពេលមួយខែ
ឬតិចជាងនេះ។ តែប្រសិនបើលើសពីនេះ
គឺច្បាប់មិនបង្គាប់ប្រើឱ្យសឡាតនៅឯផ្នូរឡើយ
ព្រោះគ្មានសេចក្ដីរាយការណ៍ពីណាពី
ﷺ
ថាលោកបានសឡាតនៅឯផ្នូរក្រោយពីគេបានបញ្ចុះសពមួយខែហើយនោះទេ។

ទីដប់ៈ
មិនអនុញ្ញាតឲ្យក្រុមគ្រួសារសពធ្វើម្ហូបអាហារសម្រាប់មនុស្សម្នាឡើយ ដោយយោងតាមសម្ដីរបស់ជើរៀរ ពិន
អាប់ទុលឡោះ អាល់ហ្ពាជើលី
ជាសហាហ្ពាត់ដ៏ឧត្ដុង្គឧត្ដមម្នាក់ رضي الله عنه ថាៈ

«كُنَّا نَعُدُّ الِاجْتِمَاعَ إِلَى أَهْلِ الْمَيِّتِ وَصَنْعَةَ الطَّعَامِ بَعْدَ الدَّفْنِ مِنَ النِّيَاحَةِ»[9]

“ពួកយើងធ្លាប់បានចាត់ទុកការប្រមូលផ្ដុំគ្នានៅឯក្រុមគ្រួសារសព
និងការធ្វើម្ហូបអាហារ(ទទួលភ្ញៀវ)បន្ទាប់ពីបញ្ចុះសពរួចថា ស្ថិតក្នុងចំណោមការទួញសោក”។

---

និងអាល់ហាគិម (៣/៣៩៩)

[1] រាយការណ៍ដោយ អ៊ីម៉ាំអះម៉ាត់ ដោយបណ្តាញអ្នករាយការណ៍ល្អ(សាណាត់ហាសាន់)។

ចំណែកឯការធ្វើម្ហូបអាហារសម្រាប់ក្រុមគ្រួសារសព

ឬសម្រាប់ភ្ញៀវរបស់ក្រុមគ្រួសារសព គឺគ្មានបញ្ហាឡើយ ហើយច្បាប់បង្គាប់ប្រើចំពោះសាច់ញាតិ

និងអ្នកជិតខាងរបស់សពឲ្យធ្វើអាហារសម្រាប់ពួកគេថែមទៀត ពីព្រោះនៅពេលដែលណាពី ﷺ លោកបានទទួលដំណឹងអំពីការស្លាប់របស់ហ្ជាក់ហ្វើរ

ពិន អាពូត៏ឡឹប رضي الله عنه នៅឯទឹកដីស្វាម លោកបានបង្គាប់ក្រុមគ្រួសាររបស់លោកឲ្យរៀបចំអាហារសម្រាប់ក្រុមគ្រួសាររបស់ហ្ជាក់ហ្វើរ

ហើយលោកបានមានប្រសាសន៍ថាៈ

«إِنَّهُ أَتَاهُمْ مَا يَشْغَلُهُمْ»[10].

"ពិតប្រាកដណាស់ អ្វីដែលធ្វើឲ្យពួកគេរវល់បានមកដល់ពួកគេ"។[2]

គ្មានទោសពៃរ៍អ្វីឡើយចំពោះក្រុមគ្រួសារសពក្នុងការអញ្ជើញអ្នកជិតខាងរបស់ខ្លួន

---

1 រាយការណ៍ដោយ អ៊ិពនូម៉ាហ្ជះ:១៦១២ និងអ៊ីម៉ាំអះម៉ាត់ (២/២០៤)

2 រាយការណ៍ដោយ មូស្លីម ក្នុងជំពូកស្តីពីសាកសព:៩៧៦, អាន់ណាសាអ៊ី ក្នុងជំពូកស្តីពីសាកសព:២០៣៤, អាពូហ្ទាវូទ ក្នុងជំពូកស្តីពីសាកសព:៣២៣៤, អ៊ិពនូម៉ាហ្ជះ ក្នុងជំពូកស្តីពីសាកសព:១៥៦៩ និង អះម៉ាត់:២/៤៤១។

ឬអ្នកដទៃទៀតឱ្យមកទទួលទានអាហារដែលគេបានជូនដល់ពួកគេ
ហើយក៏គ្មានពេលវេលាកំណត់នោះដែរសម្រាប់រឿងនេះ

តាមអ្វីដែលយើងបានដឹងអំពីច្បាប់បញ្ញត្តិឥស្លាម។

ទីដប់មួយៈ

មិនអនុញ្ញាតឲ្យស្ត្រីកាន់ទុក្ខលើសពនរណាម្នាក់លើសពីបីថ្ងៃឡើយ

លើកលែងតែចំពោះស្វាមីរបស់ខ្លួនប៉ុណ្ណោះ

ដូច្នេះ
ចាំបាច់លើស្ត្រីត្រូវកាន់ទុក្ខសពស្វាមីរបស់ខ្លួនចំនួនបួនខែ

និងដប់ថ្ងៃ លើកលែងតែស្ត្រីនោះមានផ្ទៃពោះគឺរហូតដល់ពេលដែលនាងឆ្លងទន្លេរួច
ដោយយោងតាមភស្តុតាងត្រឹមត្រូវពីស៊ុណ្ណះ

អំពីណាពី ﷺ ទាក់ទងនឹងបញ្ហានេះ។

ចំណែកឯបុរសវិញ
គឺមិនអនុញ្ញាតឱ្យកាន់ទុក្ខចំពោះនរណាម្នាក់ក្នុងចំណោមសាច់ញាតិរបស់ខ្លួន

ឬអ្នកដទៃឡើយ។

ទីដប់ពីរៈ
គេបង្គាប់ប្រើឱ្យបុរសទៅមើលផ្នូរពីពេលមួយទៅពេលមួយដើម្បីបួងសួងឲ្យអ្នកដែលបានស្លាប់

សុំក្ដីមេត្តាករុណា(ពីអល់ឡោះ)ជូនដល់ពួកគេ ក៏ដូចជាដើម្បីរំលឹកពីសេចក្ដីស្លាប់ ព្រមទាំងអ្វីដែលនឹងកើតឡើងបន្ទាប់ពីស្លាប់ ដោយយោងតាមប្រសាសន៍របស់ណាពី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«زُورُوا الْقُبُورَ، فَإِنَّهَا تُذَكِّرُكُمُ الْآخِرَةَ»[11]

«ចូរពួកអ្នកទៅមើលផ្នូរ ព្រោះពិតណាស់ វាធ្វើឱ្យពួកអ្នកនឹកឃើញដល់ថ្ងៃបរលោក»។ [1] រាយការណ៍ដោយ មូស្លីម ក្នុងសៀវភៅសហេសរបស់គាត់។

ហើយណាពី ﷺ លោកតែងបង្រៀនសហាហ្គាត់របស់លោក នៅពេលដែលពួកគេទៅមើលផ្នូរឲ្យសូត្រថា៖

«السَّلَامُ عَلَيْكُمْ أَهْلَ الدِّيَارِ مِنَ الْمُؤْمِنِينَ وَالْمُسْلِمِينَ، وَإِنَّا إِنْ شَاءَ اللَّهُ بِكُمْ لَاحِقُونَ، نَسْأَلُ اللَّهَ لَنَا وَلَكُمُ الْعَافِيَةَ، يَرْحَمُ اللَّهُ الْمُتَقَدِّمِينَ مِنَّا وَالْمُسْتَأْخِرِينَ».

“السَّلَامُ عَلَيْكُمْ أَهْلَ الدِّيَارِ مِنَ الْمُؤْمِنِينَ وَالْمُسْلِمِينَ، وَإِنَّا إِنْ شَاءَ اللَّهُ بِكُمْ لَاحِقُونَ، نَسْأَلُ اللَّهَ لَنَا وَلَكُمُ الْعَافِيَةَ، يَرْحَمُ اللَّهُ الْمُتَقَدِّمِينَ مِنَّا وَالْمُسْتَأْخِرِينَ”

[1] រាយការណ៍ដោយ អ៊ិពនូម៉ាហ្ជះ:១៥៦៩ និងបញ្ជាក់ថាពីភាពត្រឹមត្រូវ(សហេស)របស់វាដោយអាល់ហ្គានី។

(សូមសន្តិភាពកើតមានដល់អ្នករាល់គ្នាដែលជាអ្នករស់នៅក្នុងលំនៅឋាន(ផ្នូរ)នេះក្នុងចំណោមអ្នកមានជំនឿ
និងអ្នកមូស្លីមទាំងឡាយ។ ពិតប្រាកដណាស់ ប្រសិនបើអល់ឡោះមានចេតនា ពួកយើងពិតជានឹងទៅតាមក្រោយពួកអ្នក។ ពួកយើងសូមបួងសួងដល់អល់ឡោះជាម្ចាស់សូមទ្រង់មេត្តាប្រទានដល់ពួកយើង និងដល់ពួកអ្នកនូវភាពសុខសាន្ត។ សូមអល់ឡោះប្រទាននូវក្តីមេត្តាករុណាដល់អ្នកដែលបានទៅមុនក្នុងចំណោមពួកយើង និងអ្នកដែលទៅតាមក្រោយផង»។[1]

ចំណែកឯស្ត្រីវិញ គឺមិនត្រូវបានអនុញ្ញាតឱ្យទៅមើលផ្នូរឡើយ ព្រោះរ៉សូលុលឡោះ ﷺ លោកបានដាក់បណ្តាសាស្ត្រីទាំងឡាយដែលទៅមើលផ្នូរ និងម្យ៉ាង ដោយសារតែគេបារម្ភខ្លាចមានភាពវឹកវរដោយសារការទៅមើលផ្នូររបស់ពួកនាង ហើយនិងដោយសារតែការមិនសូវមានអំណត់អត់ធ្មត់របស់ពួកនាង។

ដូច្នេះឯងទើបគេមិនអនុញ្ញាតឱ្យស្ត្រីចូលរួមដង្ហែរសពទៅកាន់កន្លែងបញ្ចុះសព ព្រោះរ៉សូលុលឡោះ

---

[1] រាយការណ៍ដោយ មូស្លីម:៩៧៥

ﷺ លោកបានហាមឃាត់ស្ត្រីពីរឿងនេះ។ រីឯការសឡាតឲ្យសពនៅក្នុងម៉ាស្ជិត ឬនៅកន្លែងសឡាត គឺត្រូវបានបង្គាប់ប្រើចំពោះមនុស្សទាំងអស់គ្នា ទាំងចំពោះបុរស ទាំងចំពោះស្ត្រី។

នេះជាចំណុចចុងក្រោយនៃអ្វីដែលយើងខ្ញុំចងក្រងបាន។ សូមសន្តិភាព និងពរជ័យកើតមានដល់ណាពីយើង មូហាំម៉ាត់ ព្រមទាំងក្រុមគ្រួសារ និងបណ្តាសហាហ្ពាត់របស់លោក។

# Index


មេរៀនសំខាន់ៗសម្រាប់សាធារណជនទូទៅ........................................2
មេរៀនសំខាន់ៗសម្រាប់សាធារណជនទូទៅ........................................2
بسم الله الرحمن الرحيم........................................2
អារម្ភកថាអ្នកនិពន្ធ........................................2
មេរៀនទី១៖ ស៊ូរ៉ោះ........................................3
អាល់ហ្វាទីហះ រួមនឹងស៊ូរ៉ោះខ្លីៗមួយចំនួន........................................3
មេរៀនទី២៖........................................4
គោលគ្រឹះនៃសាសនាអ៊ីស្លាម........................................4
មេរៀនទី៣៖ គោលគ្រឹះនៃជំនឿ........................................7
មេរៀនទី៤៖ ប្រភេទនៃតាវហេទ........................................8
និងប្រភេទនៃអំពើស្ហ៊ីរិក........................................8
មេរៀនទី៥៖ អៀហសាន(អំពើល្អ)........................................17
មេរៀនទី៦៖ លក្ខខណ្ឌនៃសឡាត........................................17
មេរៀនទី៧៖ គោលគ្រឹះ(រូកុន)នៃសឡាត........................................18
មេរៀនទី៨៖........................................18
ប្រការចាំបាច់(វ៉ាជិប)នៃសឡាត........................................18
មេរៀនទី៩៖ ពន្យល់អំពីការសូត្រតះយិត........................................19
មេរៀនទី១០៖ ប្រការគប្បីធ្វើ(ស៊ូណិត)នៃសឡាត........................................23
មេរៀនទី១១៖........................................26
ប្រការដែលនាំឲ្យខូចសឡាត........................................26
មេរៀនទី១២៖ លក្ខខណ្ឌនៃវូហ្ហ៊ុ........................................26
មេរៀនទី១៣៖........................................27
កាតព្វកិច្ចនៃវូហ្ហ៊ុ........................................27
មេរៀនទី១៤៖ ប្រការដែលនាំឲ្យដាច់........................................28
ឬខូចវូហ្ហ៊ុ........................................28

មេរៀនទី១៥៖
ប្រកាន់ខ្ជាប់នឹងចរិតលក្ខណៈឥស្លាមសម្រាប់អ្នកមូស្លីមគ្រប់រូប ........ 30
មេរៀនទី១៦៖ ប្រកាន់ខ្ជាប់នឹងសុជីវធម៌ឥស្លាម ........ 31
មេរៀនទី១៧៖ ព្រមានពីប្រការស្ទីរិក ........ 32
និងអំពើបាបគ្រប់ប្រភេទ ........ 32
មេរៀនទី១៨៖ ការរៀបចំសព ........ 33
សឡាតឲ្យសព និងបញ្ចុះសព ........ 33
ត្រូវបិទបាំងកេរខ្មាសរបស់សព។ ........ 35
បន្ទាប់មក លើកសពឡើងខ្ពស់បន្តិច ហើយសង្កត់ពោះសពថ្នមៗ។ បន្ទាប់មក អ្នកងូតទឹកឲ្យសពត្រូវយកក្រណាត់ ........ 35
ឬអ្វីដែលស្រដៀងគ្នានេះមកពាក់ដៃ
រួចលាងសម្អាតកេរខ្មាសសព។ បន្ទាប់មកទៀត ........ 35
ត្រូវយកវូហ្ទុឲ្យសពដូចដែលគេយកវូហ្ទុដើម្បីសឡាត។ ក្រោយមក ត្រូវលាងក្បាល ........ 35
និងពុកចង្ការរបស់សពដោយទឹកដែលលាយនឹងស្លឹកពុទ្រា
ឬអ្វីដែលស្រដៀងគ្នានេះ។ បន្ទាប់មកទៀត ........ 35
ត្រូវលាងចំហៀងខ្លួនខាងស្តាំនៃសព
រួចបន្តទៅចំហៀងខ្លួនខាងឆ្វេង។ ក្រោយមកទៀត គេត្រូវងូតទឹកឲ្យសពតាមរបៀបនេះជាលើកទីពីរ ........ 35
និងលើកទីបីទៀត ដោយរាល់ៗលើក ត្រូវយកដៃសង្កត់ពោះសពថ្នមៗ។
ប្រសិនបើមានអ្វីមួយចេញពីខ្លួនសព(ដូចជាកាកសំណល់) ........ 35
ត្រូវលាងសម្អាតវាចេញ ហើយត្រូវទប់កន្លែងនោះដោយដុំសំឡី ឬរបស់ដែលស្រដៀងគ្នានេះដើម្បីកុំឲ្យវាចេញមកទៀត។ ........ 36
ប្រសិនបើនៅតែមិនអាចទប់ជាប់(នៅតែហូរមកទៀត)
គឺត្រូវប្រើដីឥដ្ឋស្អាត ........ 36

ឬមធ្យោបាយវេជ្ជសាស្ត្រទំនើប ដូចជាបង់ស្អិត ឬអ្វីដែលស្រដៀងគ្នានេះ។ ..... 36